# មន្ទីរកសិកម្មខេត្តកណ្តាល

# ដំណាំម្ទេស




**អាស័យដ្ឋានទំនាក់ទំនង ផ្លូវលេខ ១០៣ (តាខ្មៅ)**

**ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)**

**(០១២ ៨២៤ ៤២៥)**



**ឧបត្ថម្ភដោយ: អង្គការវីវីអូប៊ី VVOB**

**ឆ្នាំ ២០១០**


# ដំណាំម្ទេស

## ១. លក្ខណៈទូទៅ

ដំណាំម្ទេស គឺត្រូវបានគេទទួលស្គាល់ និងពេញនិយមប្រើប្រាស់ជាយូរយារណាស់មកហើយ។ លក្ខណៈពិសេសរបស់ម្ទេសគឺមានរសជាតិហឹរ ពេលទុំមានពណ៌ក្រហម មានក្លិនឆ្ងួល ហើយអាចលូតលាស់យូរឆ្នាំជាងពួកដំណាំក្នុងគ្រួសារដូចគ្នា។

## ២. ការជ្រើសរើសពូជ

ការជ្រើសរើសពូជត្រូវមានលក្ខណៈសម្បត្តិដូចតទៅ:

- ពូជសុទ្ធ មានប្រភពច្បាស់លាស់ និងផ្តល់ឱ្យទិន្នផលខ្ពស់
- ពូជធន់ទៅនឹងជម្ងឺ-សត្វល្អិត និងមានអាយុកាលខ្លី
- ពូជដែលមានលក្ខណៈសមស្របទៅនិងការដាំដុះ
- ពូជដែលមិនប្រកាន់រដូវ គឺអាចលូតលាស់បានគ្រប់រដូវ
- ពូជមានគុណភាពល្អ និងមានដំណុះខ្ពស់លើស ៨៥%

## ៣. ការជ្រើសរើសពេលវេលាដាំដុះ

ពេលវេលាសមស្របសំរាប់ការដាំដុះម្ទេស គឺមានពីរ:

- ចំពោះតំបន់លិចទឹក គឺចាប់ផ្តើមពីខែ តុលា ដល់ខែមិនា ហើយពន្យាពេលប្រមូលផលរហូតដល់ខែកក្កដា ឬសីហា
- ចំពោះតំបន់មិនលិចទឹក គឺចាប់ផ្តើមពីខែមិថុនា ឬខែកក្កដា ហើយធ្វើការប្រមូលផលបញ្ចប់នៅខែវិច្ឆិកា ឬធ្នូ។

## ៤. ការជ្រើសរើស និងរៀបចំដី

<u>**ការជ្រើសរើសដី**</u>

- ដីមានជីជាតិល្អ នៅក្បែរប្រភពទឹក
- ដីល្បាប់ល្បាយខ្សាច់ ធូរ សម្បូរទៅដោយជាតិមមោគ និងសារធាតុចិញ្ចឹមខ្ពស់
- ជៀសវាងការជ្រើសរើសដីដែលដាំម្ទេសយូរឆ្នាំ ឬពពួកគ្រួសារតែមួយដូចជាប៉េងបោះ ត្រប់......។

<u>**ការរៀបចំដី**</u>

ការរៀបចំដីមានសារៈសំខាន់ណាស់ ព្រោះវាជួយធ្វើឱ្យដីធូរ មានខ្យល់ចេញចូលគ្រប់គ្រាន់ និងរក្សាសំណើមដីបានល្អ ព្រមទាំងជួយធ្វើឱ្យមានលំនឹង ពពួកបាក់តេរីមានប្រយោជន៏ ដោយត្រឡប់ពីលើចុះក្រោម និងពីក្រោមឡើងលើ។

ការភ្ជួរឱ្យបានជ្រៅ គឺធានាដល់ការចាក់ឬសរបស់ដំណាំ ព្រោះឬស គឺជាប្រព័ន្ធមួយសំរាប់ជួយដល់រុក្ខជាតិក្នុងការជញ្ជូនយកសារធាតុចិញ្ចឹម និងទឹកទៅផ្នែកសរីរាង្គដទៃទៀត។

ក្រៅពីភ្ជួរឱ្យបានជ្រៅ ដីត្រូវរាស់ឱ្យបានហ្មត់ល្អ និងកៀរឱ្យបានរាបស្មើ ដោយប្រមូលយកកំទេចកំទីរុក្ខជាតិដែលនៅសេសសល់ពីរដូវមុន រួមជាមួយស្មៅចង្រៃចេញ។

<u>**ការលើករង**</u>

ក្រោយពីរៀបចំដីរួចហើយ គេត្រូវលើករងឱ្យបានខ្ពស់គឺពី ២០-៣០សង្ទីម៉ែត្រ (អាស្រ័យទៅតាមតំបន់លិចទឹក ឬមិនលិចទឹក) ទទឹងរងអាស្រ័យលើវិធីសាស្ត្រដាំដុះ(បើដាំមួយជួរ ទទឹងរងគឺ ៦០-៨០សង្ទីម៉ែត្រ បើដាំពីរជួរ ទទឹងរង គឺ ១០០-១២០សង្ទីម៉ែត្រ) រីឯបណ្តោយគឺអាស្រ័យទៅតាមលទ្ធភាពជាក់ស្តែងរបស់ដី។

## ៥. បច្ចេកទេសដាំដុះ

ដំណាំម្ទេសអាចដាំដុះដោយការបណ្តុះកូនដូចជាត្រប់ និងប៉េងបោះដែរ។

<u>**ការបណ្តុះកូន**</u>

គេអាចសាបកូនដោយគ្រាន់តែយកគ្រាប់ពូជទៅសាបលើថ្នាលផ្ទាល់ រហូតដល់វាមានអាយុ ៣៥-៤០ថ្ងៃ ពោលគឺមានស្លឹក ៣-៤ ទើបយកទៅដាំ។ តែដើម្បីឱ្យកូនម្ទេសលូតលាស់

បានលឿនហើយឆាប់បានយកទៅដាំ គេប្រើវិធីសាស្ត្រផ្សេងមួយទៀត គឺត្រូវយកគ្រាប់ម្ទេសទៅហាលថ្ងៃ ១-២ម៉ោង ឱ្យក្តៅ រួចយកទៅត្រាំទឹកក្តៅក្នុងកំរិត ៥០អង្សាសេ រយៈពេល ២០-៣០នាទី បន្ទាប់ត្រាំទឹកធម្មតារយៈពេលមួយយប់ ទើបស្រង់យកទៅផ្អាប់នៅកន្លែងសើម-ងងឹត ២យប់ទៀត ពេលនោះគ្រាប់ពូជនឹងចាប់ដុះចេញពន្លក ហើយអាចយកទៅសាបលើថ្នាល។ រយៈពេល ១០-១២ថ្ងៃ ពេលកូនម្ទេសដុះចេញស្លឹកតំបូង២សន្លឹក គេអាចដកយកទៅស្ទូងផ្សាំក្នុងកន្ទោងនៅក្រោមផ្ទះសំណាញ់ ឬគ្របការពារកំដៅថ្ងៃរយៈពេល ២-៣ថ្ងៃ។ គេអាចស្រោចទឹកមួយថ្ងៃពីរដង (ព្រឹក-ល្ងាច)។ ក្រោយផ្សាំបានរយៈពេល ៧ថ្ងៃ គេអាចយកជីអ៊ុយរ៉េចំនួន ១ ស្លាបព្រាបាយមកលាយទឹក ១៥លីត្រ ស្រោចឱ្យជោគ រួចហើយស្រោចទឹកធម្មតាលាងតាមក្រោយ។ វិធីនេះជួយឱ្យកូនម្ទេសលូតលាស់ស្មើគ្នាហើយថ្លោសល្អ។ ក្រោយផ្សាំរយៈពេល ១៨-២០ថ្ងៃ (ពេលកូនម្ទេសមានស្លឹក៤-៥ និងមានកំពស់ ៧-១២សង្ទីម៉ែត្រ) គឺអាចយកទៅដាំបានហើយ។

**<u>ការប្រើប្រាស់ជី</u>**

វិធីសាស្ត្រដាក់ជីមានដូចតទៅ:

- ប្រើប្រាស់ជីកំប៉ុស្តិ ៧-១០តោន និងជី ១៥-១៥-១៥ ចំនួន ២០០គីឡូក្រាមក្នុងមួយហិចតា សំរាប់ដាក់ទ្រាប់បាតមុនពេលដាំ ឬស្ទូង
- ដាក់បំប៉នក្រោយពេលដាំ ឬស្ទូងរយៈពេល ១៥-២០ថ្ងៃ ប្រភេទជី ១៥-១៥-១៥ ចំនួន ២០០គីឡូក្រាម និងជីប៉ូតាស្យូមក្លរួ (គជល) ចំនួន ៥០គីឡូក្រាម ក្នុងមួយហិចតា
- ដាក់បំប៉នចុងក្រោយបង្អស់ គឺក្រោយពេលប្រមូលផលលើកទី ១ ប្រភេទជី ១៥-១៥-១៥ ចំនួន ១០០-១៥០ គីឡូក្រាមទៅតាមសភាពលូតលាស់របស់ដំណាំ។

**<u>ការថែទាំ</u>**

ការថែទាំរាប់ទាំងការស្រោចស្រព ការសំអាតស្មៅ ជ្រុំដី ពូនគល់ និងដោតចំណារ។

ដំណាំម្ទេសត្រូវការទឹកជាមធ្យម (សំណើមដី ៦៥-៧០%) ដូច្នេះនៅរយៈពេល ៣ ថ្ងៃដំបូងក្រោយស្ទូង គេត្រូវស្រោចដោយប៉ោតថ្នមៗ បន្ទាប់មកគេបញ្ជាងទឹកឱ្យបាន ២ភាគ៣ នៃកំពស់រង ហើយបិទរក្សាទឹកនៅក្នុងចន្លោះរងនោះ។ គេអាចស្រោចទឹកដោយប៉ោតរៀងរាល់ថ្ងៃ ឬបញ្ជូលទឹក ២-៣ ថ្ងៃម្តង ទៅតាមប្រភេទដី និងអាកាសធាតុជាក់ស្តែង។

ការសំអាតស្មៅលើកទី ១ ត្រូវធ្វើនៅក្រោយពេលស្ទូង ១០-១៥ថ្ងៃ ដោយជ្រុំដីឱ្យផុស ហើយពូនរងសារជាថ្មីម្តង ទៀត និងចាប់ផ្តើមដោតចំណារខ្ចីៗ (កំពស់ ៧០-១០០ សង្ទីម៉ែត្រ)។ ការសំអាតស្មៅ និងជ្រុំដីលើកទី ២ គឺធ្វើនៅ មុនពេលចេញផ្កា (ក្រោយដាំ ២០-២៥ថ្ងៃ )។ លើកទី ៣ គឺគ្រាន់តែសំអាតស្មៅតែប៉ុណ្ណោះ (ការពារកុំឱ្យដាច់ឫស) គឺនៅពេលដែលម្ទេសផ្លែ ១០០%។

## ៦. ការប្រមូលផល

ការប្រមូលផលអាចធ្វើឡើងក្រោយពីដាំ ឬស្ទូងរយៈពេល ៦៥-៨០ថ្ងៃ អាស្រ័យទៅតាមប្រភេទពូជ និងរដូវកាល។ ការប្រមូលផលចែកចេញជាបីផ្នែក:

**<u>ការប្រមូលផលសំរាប់ទីផ្សារ</u>**

ការប្រមូលផលសំរាប់ទីផ្សារ គឺអាចធ្វើឡើងនៅពេលដែលឃើញថាម្ទេសទុំស្រុះគ្នា រវាងផ្លែដែលចេញមុន និងផ្លែដែលចេញក្រោយ (ម្ទេសផ្លែបន្តគ្នាពីក្រោមឡើងលើ)។

**<u>ការប្រមូលផលសំរាប់កែច្នៃ</u>**

ការប្រមូលផលសំរាប់កែច្នៃ គឺអាចធ្វើឡើងយឺតជាងការប្រមូលផលសំរាប់ទីផ្សារ ៤-៥ថ្ងៃ (ដោយទុកឱ្យទុំក្រហមពិតប្រាកដ ព្រោះគេយកទៅកែច្នៃធ្វើជាម្ទេសក្រៀម ឬទឹកម្ទេស)។

**<u>ការប្រមូលផលសំរាប់ទុកពូជ</u>**

ការប្រមូលផលសំរាប់ទុកពូជ មានលក្ខណៈខុសពីការប្រមូលផលទាំងពីរខាងលើ គឺមិនទុកឱ្យមានចំនួនផ្លែច្រើនទេ។ គេធ្វើការកាត់ផ្លែផ្នែកខាងលើចោល ដោយរក្សាទុកផ្លែតែត្រឹមចំនួនសមស្រប (ផ្លែដែលមានជម្ងឺ និងរងសត្វល្អិត បំផ្លាញមិនប្រមូលឡើយ)។ ពេលផ្លែម្ទេសទុំពិតប្រាកដ តាមអាយុកាលវា គេបេះផ្លែម្ទេសយកមករក្សាទុកចំនួន ២-៣ថ្ងៃ នៅក្នុងជិរកត្រជាក់ ហើយបន្ទាប់មកទៀតទើបវះយកគ្រាប់ ទៅត្រាំទឹករយៈពេល ១០-១២ម៉ោង រួចទើបយកមកលាង ទឹកសំអាតគ្រាប់ពូជ និងដាក់ហាលថ្ងៃឱ្យស្ងួតរយៈពេល ១-២ថ្ងៃ ទើបគេយកទៅរក្សាទុកនៅកន្លែងស្ងួត។